សុខភាព និងជីវិត
កាន់តែប្រសើរ



# រៀបចំសុវត្ថិភាពកូន បន្ថែមការការពារទ្វេដង

## អត្ថប្រយោជន៍ការពារជំងឺធ្ងន់ធ្ងរសម្រាប់កូន

កូនរបស់អ្នកគឺជាមោទនភាព សុភមង្គល និងជាភាពរីករាយរបស់អ្នក ហើយសុវត្ថិភាព និងសុខភាពរបស់ពួកគេគឺជាកត្តាចម្បងយ៉ាងសំខាន់សម្រាប់អ្នក។ ប្រសិនបើកូនរបស់អ្នកមានជំងឺធ្ងន់ធ្ងរ វាពិតជាលំបាកក្នុងការទទួលបានជំនួយផ្នែកហិរញ្ញវត្ថុភ្លាមៗ ដើម្បីចំណាយលើការព្យាបាលឱ្យបានទាន់ពេលវេលា ដើម្បីជួយឱ្យបានជាសះស្បើយ។

ផលិតផលធានារ៉ាប់រងបន្ថែម “**អត្ថប្រយោជន៍ការពារជំងឺធ្ងន់ធ្ងរសម្រាប់កូន**” គឺជាគម្រោងធានារ៉ាប់រងដំបូងគេដែលផ្តល់ការការពារលើជំងឺធ្ងន់ធ្ងរច្រើនជាង 30 ប្រភេទ ដែលអាចកើតឡើងចំពោះកុមារ ហើយគម្រោងនេះអាចផ្តល់ការការពារចាប់ពីពេលដែលទារកមានអាយុ 30 ថ្ងៃ។ គម្រោងនេះ ជាជំនួយយ៉ាងសំខាន់ផ្នែកហិរញ្ញវត្ថុដ៏មានតម្លៃ ដែលអាចជួយសម្រាលបន្ទុកលើចំណាយព្យាបាលជំងឺដ៏ចាំបាច់ ក្នុងករណីធ្វើរោគវិនិច្ឆ័យឃើញថាមានជំងឺធ្ងន់ធ្ងរតាំងពីដំណាក់កាលដំបូង។

# អត្ថប្រយោជន៍ពិសេសសំខាន់ៗ

## ផ្ដល់ការការពារ 5 ចំនុចសំខាន់ៗ

### ការពារលើជំងឺធ្ងន់ធ្ងរច្រើនជាង 30 ប្រភេទអាចកើតឡើងចំពោះកុមារ

រួមមានជំងឺ មហារីក ខួរក្បាល ផ្លូវដង្ហើម បេះដូង
តម្រងនោម ការផ្លាស់ប្ដូរសរីរាង្គ ជំងឺដៃ ជើង និងមាត់ ជាដើម



**អត្ថប្រយោជន៍លើជំងឺធ្ងន់ធ្ងរដំណាក់កាលដំបូង***

ផ្ដល់សំណង 100% ក្នុងករណីការធ្វើរោគវិនិច្ឆ័យឃើញថាមានជំងឺធ្ងន់ធ្ងរដំណាក់កាលដំបូង

**អត្ថប្រយោជន៍លើជំងឺធ្ងន់ធ្ងរដំណាក់កាលចុងក្រោយ***

ផ្ដល់សំណងទ្វេដង ក្នុងករណីការធ្វើរោគវិនិច្ឆ័យឃើញថាមានជំងឺធ្ងន់ធ្ងរដំណាក់កាលចុងក្រោយ

**គម្រោងធានារ៉ាប់រងលើជំងឺធ្ងន់ធ្ងរដំបូងគេក្នុងទីផ្សារសម្រាប់កូន**

ការពារចាប់ពីពេលដែលទារកមានអាយុ 30 ថ្ងៃ

**អត្ថប្រយោជន៍លើជម្រើសទទួលយកការធានារ៉ាប់រង (GIO)****

មានសិទ្ធិក្នុងការទិញធានារ៉ាប់រងលើជំងឺធ្ងន់ធ្ងរថ្មី ដោយពុំចាំបាច់ឆ្លងកាត់ការវាយតម្លៃហានិភ័យធានារ៉ាប់រងជាថ្មី
(**ខ និងលក្ខខណ្ឌត្រូវបានអនុវត្ត)

* ការទូទាត់សរុបដែលបានធ្វើឡើងសម្រាប់ជំងឺធ្ងន់ធ្ងរដំណាក់កាលដំបូង និងជំងឺធ្ងន់ធ្ងរដំណាក់កាលចុងក្រោយ សម្រាប់អ្នកត្រូវបានធានារ៉ាប់រង មិនត្រូវលើសពី 200% នៃទឹកប្រាក់ធានារ៉ាប់រង នៃផលិតផលធានារ៉ាប់រងបន្ថែម □អត្ថប្រយោជន៍ការពារជំងឺធ្ងន់ធ្ងរសម្រាប់កូន□។

## ឧទាហរណ៍៖

### ការពារកូនជាទីស្រលាញ់លោកអ្នកពីជំងឺធ្ងន់ធ្ងរ

**លោកស្រី បុប្ផា** អាយុ 28 ឆ្នាំ ជាម្តាយរបស់កូនប្រុស អាយុ 3 ឆ្នាំឈ្មោះ**សិទ្ធិស័ក្តិ**។ លោកស្រីបានរៀបចំគម្រោងការការពារកូនរបស់គាត់ ជាមួយផលិតផលធានារ៉ាប់រងមូលដ្ឋាន “**AIA ការពារកូន**” ។ លើសពីនេះ លោកស្រីចាប់អារម្មណ៍គម្រោងដំណោះស្រាយផ្នែកសុខភាព ដើម្បីជួយសម្រាលថ្លៃចំណាយព្យាបាល ប្រសិនបើកូនរបស់លោកស្រីធ្លាក់ខ្លួនឈឺក្នុងស្ថានភាពធ្ងន់ធ្ងរ។ **លោកស្រី បុប្ផា** បានសម្រេចជ្រើសរើសបន្ថែមការការពារជាមួយផលិតផលធានារ៉ាប់រងបន្ថែម “**អត្ថប្រយោជន៍ការពារជំងឺធ្ងន់ធ្ងរសម្រាប់កូន**” ដើម្បីធានាថាកូនរបស់គាត់ទទួលបានការធានាដ៏ពេញលេញ ជាមួយនឹងចំនួនទឹកប្រាក់ធានារ៉ាប់រងបន្ថែមចំនួន US$10,000 ។ លោកស្រីជ្រើសរើសរយៈពេលនៃការធានារ៉ាប់រងចំនួន 19 ឆ្នាំ ជាមួយនឹងការទូទាត់បុព្វលាភធានារ៉ាប់រងរយៈពេល 15 ឆ្នាំ និងការបង់បុព្វលាភធានារ៉ាប់រងប្រចាំឆ្នាំចំនួន **US$18.50** (ទឹកប្រាក់បុព្វលាភធានារ៉ាប់រងនេះសម្រាប់តែផលិតផលធានារ៉ាប់រងបន្ថែមប៉ុណ្ណោះ)។

## អត្ថប្រយោជន៍ដែលក្រុមគ្រួសារ លោកស្រី បុប្ផា នឹងទទួលបាន៖

ក្នុងករណីមានគ្រោះអកុសលណាមួយបានកើតឡើងចំពោះ **សិទ្ធិស័ក្តិ** ដោយសារជំងឺធ្ងន់ធ្ងរក្នុងកំឡុងពេលធានារ៉ាប់រង ក្រុមគ្រួសាររបស់ **សិទ្ធិស័ក្តិ** នឹងទទួលបានជំនួយផ្នែកហិរញ្ញវត្ថុភ្លាមៗ ក្នុងការព្យាបាលទាន់ពេលវេលា និងអាចជួយ **សិទ្ធិស័ក្តិ** មានឱកាសបានជាសះស្បើយឡើងវិញ។

| ប្រភេទអត្ថប្រយោជន៍ធានារ៉ាប់រង | អត្ថប្រយោជន៍ផ្តល់ជូន |
|---|---|
| អត្ថប្រយោជន៍លើជំងឺធ្ងន់ធ្ងរដំណាក់កាលដំបូង | US$10,000 |
| អត្ថប្រយោជន៍លើជំងឺធ្ងន់ធ្ងរដំណាក់កាលចុងក្រោយ* | US$20,000 |

ក្នុងករណីដែល **សិទ្ធិស័ក្តិ** មានសុខភាពមាំមួន ហើយគាត់មិនទាមទារអត្ថប្រយោជន៍ជំងឺធ្ងន់ធ្ងរដំណាក់កាលដំបូង ឬដំណាក់កាលចុងក្រោយ អត្ថប្រយោជន៍ពិសេសដែលត្រូវផ្តល់ជូនទៅកាន់ **សិទ្ធិស័ក្តិ** នៅពេលសម្រេចទទួលយកការការពារលើជំងឺធ្ងន់ធ្ងរថ្មីបន្តទៀតនៅពេលដល់កាលកំណត់នៃបណ្ណសន្យារ៉ាប់រង។

| ប្រភេទអត្ថប្រយោជន៍ធានារ៉ាប់រង | អត្ថប្រយោជន៍ផ្តល់ជូន |
|---|---|
| អត្ថប្រយោជន៍លើជម្រើសទទួលយកការធានារ៉ាប់រង(GIO) ** | មានជម្រើសក្នុងការទិញធានារ៉ាប់រងលើជំងឺធ្ងន់ធ្ងរថ្មីដោយមិនចាំបាច់ឆ្លងកាត់ការវាយតម្លៃហានិភ័យធានារ៉ាប់រងជាថ្មី នៅចុងបញ្ចប់នៃបណ្ណសន្យារ៉ាប់រង។ |

* ប្រសិនបើអត្ថប្រយោជន៍លើជំងឺធ្ងន់ធ្ងរដំណាក់កាលដំបូងត្រូវបានធ្វើសំណងជូនរួចហើយ នោះអត្ថប្រយោជន៍លើជំងឺធ្ងន់ធ្ងរដំណាក់កាលចុងក្រោយនឹងអាចផ្តល់ជូនបានត្រឹមចំនួន US$10,000។

** ជម្រើសទទួលយកការធានារ៉ាប់រង(GIO) ត្រូវអនុវត្តតាម ខ និងលក្ខខណ្ឌ។

# តារាងជំងឺធ្ងន់ធ្ងរសម្រាប់កុមារ

| ប្រភេទជំងឺធ្ងន់ធ្ងរ | ជំងឺធ្ងន់ធ្ងរដំណាក់កាលដំបូង | ជំងឺធ្ងន់ធ្ងរដំណាក់កាលចុងក្រោយ |
|---|---|---|
| ដុំមហារីក | 1. ដុំមហារីក<br>• ជាលិកាមហារីកទីតាំងដើម<br>• មហារីកក្រពេញប្រូស្តាតដំណាក់កាលដំបូង<br>• មហារីកក្រពេញទីរ៉ូអ៊ីតដំណាក់កាលដំបូង<br>• មហារីកប្លោកនោមដំណាក់កាលដំបូង<br>• មហារីកគ្រាប់ឈាម ស រ៉ាំរ៉ៃដំណាក់កាលដំបូង | 16. ជំងឺមហារីកធ្ងន់ធ្ងរ |
| ខួរក្បាល | 2.ជំងឺរលាកខួរក្បាល ដែលអាចជាសះស្បើយពេញលេញ | 17. ជំងឺរលាកខួរក្បាល ដែលខូចសរសៃប្រសាទជាអចិន្ត្រៃយ៍ |
| | 3.ជំងឺរលាកស្រោមខួរបង្កដោយបាក់តេរីដែលអាចជាសះស្បើយពេញលេញ | 18. ជំងឺរលាកស្រោមខួរក្បាលបង្កដោយបាក់តេរី ដែលខូចសរសៃប្រសាទជាអចិន្ត្រៃយ៍ |
| ជំងឺផ្លូវដង្ហើម | 4. ជំងឺហឺតកម្រិតធ្ងន់ធ្ងរ | 19. ជំងឺហឺតកម្រិតធ្ងន់ធ្ងររ៉ាំរ៉ៃ ដែលមិនអាចជាសះស្បើយឡើងវិញ |
| | 5. ស្ថានភាពជំងឺឆ្អុតជ្រូក ដែលតម្រូវឱ្យប្រើប្រាស់ឧបករណ៍បញ្ចូលបំពង់ខ្យល់ជាជំនួយដល់ការដកដង្ហើម | 20. ជំងឺឆ្អុតជ្រូកកម្រិតធ្ងន់ធ្ងរ |
| លំពែង | 6. ជំងឺទឹកនោមផ្អែម ដែលខូចមុខងារអាំងស៊ុយលីន (ផ្អែកលើការធ្វើរោគវិនិច្ឆ័យ) | 21. ជំងឺទឹកនោមផ្អែមសម្រាប់កុមារ ដែលខូចមុខងារអាំងស៊ុយលីនជាអចិន្ត្រៃយ៍ |
| បេះដូង | 7. ជំងឺកាវ៉ាសាគី (ផ្អែកលើការធ្វើរោគវិនិច្ឆ័យ) | 22. ជំងឺកាវ៉ាសាគីកម្រិតធ្ងន់ធ្ងរ រួមជាមួយផលវិបាកចំពោះបេះដូង |
| | 8. ការព្យាបាលផ្នែកខាងក្នុងនៃសរសៃឈាមនៃ Aortic Disease ឬ Aortic Aneurysm | 23. ការវះកាត់ដោយបើកសរសៃនៃសរសៃស្រោបបេះដូង (អាទៃក្សួណា ឬអាអក) |
| សន្លាក់ | 9. ជំងឺរលាកសន្លាក់រ៉ាំរ៉ៃសម្រាប់កុមារ (ផ្អែកលើការធ្វើរោគវិនិច្ឆ័យ) | 24. ជំងឺរលាកសន្លាក់រ៉ាំរ៉ៃសម្រាប់កុមារ ដែលមិនអាចជាសះស្បើយឡើងវិញ |
| តម្រងនោម | 10. ការរលាកសរីរាង្គនៅក្នុងតម្រងនោម (ផ្អែកលើការធ្វើរោគវិនិច្ឆ័យ) | 25. ការរលាកសរីរាង្គនៅក្នុងតម្រងនោម ដែលមិនអាចជាសះស្បើយវិញបាន រួមជាមួយរោគសញ្ញានៃជំងឺតម្រងនោម |
| | 11. រោគសញ្ញានៃជំងឺតម្រងនោម ដែលតម្រូវឱ្យមានការសម្រាកព្យាបាលនៅមន្ទីរពេទ្យ | 26. រោគសញ្ញានៃជំងឺតម្រងនោមកម្រិតធ្ងន់ធ្ងរ |
| ប្រព័ន្ធប្រសាទ | 12. ជំងឺគ្រុនស្វិតដៃជើង (Poliomyelitis) កម្រិតស្រាល | 27. ជំងឺគ្រុនស្វិតដៃជើង (Poliomyelitis) |
| រាងកាយ | 13. ជំងឺជាត់ក្នុងវ័យជំទង់ (ផ្អែកលើការធ្វើរោគវិនិច្ឆ័យ) | 28. ជំងឺជាត់ក្នុងវ័យជំទង់ (ដែលតម្រូវឱ្យមានការវះកាត់) |
| ប្រម៉ាត់ | 14. ជំងឺត្បៀតថង់ទឹកប្រម៉ាត់ (ផ្អែកលើការធ្វើរោគវិនិច្ឆ័យ) | 29. ជំងឺត្បៀតថង់ទឹកប្រម៉ាត់ ដែលតម្រូវឱ្យមានការវះកាត់ប្តូរថ្លើម |
| ខួរឆ្អឹងខ្នង | 15. ជំងឺស្លេកស្លាំង (ដែលបណ្តាលមកពីកង្វះគ្រាប់ឈាមក្រហម) អាផ្លាស្ទិក ដែលអាចជាសះស្បើយវិញបាន | 30. ជំងឺស្លេកស្លាំង (ដែលបណ្តាលមកពីកង្វះគ្រាប់ឈាមក្រហម) អាផ្លាស្ទិក ដែលមិនអាចជាសះស្បើយវិញបាន |
| ការផ្លាស់ប្តូរសរីរាង្គ | | 31. ការផ្លាស់ប្តូរសរីរាង្គ<br>• ការផ្លាស់ប្តូរតម្រងនោម<br>• ការផ្លាស់ប្តូរបេះដូង<br>• ការផ្លាស់ប្តូរសួត<br>• ការផ្លាស់ប្តូរលំពែង<br>• ការផ្លាស់ប្តូរថ្លើម |
| | | 32. ការផ្លាស់ប្តូរខួរឆ្អឹង |
| ដៃ ជើងនិងមាត់ | | 33. ជំងឺធ្ងន់ធ្ងរឆ្លងនៅលើដៃ ជើង និងមាត់ដែលមានផលវិបាកគំរាមកំហែងដល់អាយុជីវិត |

## ព័ត៌មានសង្ខេបស្ដីពីផលិតផល

- អាយុចុះឈ្មោះដំបូង
  30 ថ្ងៃ -17 ឆ្នាំ
- អាយុផុតកំណត់
  22 ឆ្នាំ
- រយៈពេលនៃការធានារ៉ាប់រង
  ដូចគ្នាទៅនឹងរយៈពេលនៃការធានារ៉ាប់រងសម្រាប់ផលិតផលធានារ៉ាប់រងមូលដ្ឋានដែលភ្ជាប់ជាមួយ ដោយអនុលោមតាមអាយុរបស់អ្នកត្រូវបានធានារ៉ាប់រង អតិបរមាត្រឹម អាយុ 22 ឆ្នាំ។
- រយៈពេលនៃការបង់បុព្វធានារ៉ាប់រង
  ដូចគ្នាទៅនឹងរយៈពេលនៃការធានារ៉ាប់រងសម្រាប់ផលិតផលធានារ៉ាប់រងបន្ថែមនេះ ឬអនុលោមតាមរយៈពេលនៃការបង់បុព្វលាភធានារ៉ាប់រងសម្រាប់ផលិតផលធានារ៉ាប់រងមូលដ្ឋានដែលភ្ជាប់ជាមួយ។

## ការទាមទារសំណង

ប្រសិនសិនបើអ្នក ចង់ធ្វើការទាមទារសំណង អ្នកត្រូវបំពេញទម្រង់បែបបទទាមទារសំណង និងផ្តល់ភស្តុតាង ក្នុងកំឡុងពេល 90 ថ្ងៃនៃថ្ងៃប្រតិទិន ពីការកើតឡើងនៃព្រឹត្តិការណ៍ដែលត្រូវបានធានារ៉ាប់រង។ អ្នកអាចទាញយកទម្រង់បែបបទទាមទារសំណងពីគេហទំព័ររបស់យើង គឺ **aia.com.kh** ឬ ពីទីប្រឹក្សាផែនការជីវិត AIA។

រាល់ឯកសារ និងភស្តុតាងចាំបាច់ដែលត្រូវដាក់ភ្ជាប់ជាមួយនឹងទម្រង់បែបបទទាមទារសំណងមកកាន់ក្រុមហ៊ុន AIA មានដូចជា វិញ្ញាបនបត្រវេជ្ជសាស្រ្ត របាយការណ៍ចេញពីមន្ទីរពេទ្យបញ្ជាក់ពីការធ្វើរោគវិនិច្ឆ័យឃើញថាមានជំងឺធ្ងន់ធ្ងរ លទ្ធផលវិភាគ biopsy ឬរបាយការណ៍ Anapathology (ចំពោះជំងឺមហារីក) និងឯកសារវេជ្ជសាស្រ្តផ្សេងទៀត។ រាល់ឯកសារវេជ្ជសាស្រ្តទាំងអស់ ត្រូវតែទទួលស្គាល់ពីមន្ទីរវេជ្ជសាស្រ្តដែលមានអាជ្ញាបណ្ណស្របច្បាប់លើសេវាព្យាបាលវេជ្ជសាស្រ្តនៅក្នុងប្រទេស។

អ្នកទាមទារសំណងអាចស្នើសុំសំណង ប្រសិនបើករណីត្រូវទាមទារសំណង និងការព្យាបាលផ្នែកវេជ្ជសាស្រ្តកើតឡើង ក្នុងកំឡុងពេលបណ្ណសន្យារ៉ាប់រងកំពុងមានសុពលភាព។

**ការទទួលយកសំណើធានារ៉ាប់រង**
សូមទាក់ទង ទីប្រឹក្សាផែនការជីវិត AIA ឬសេវាបម្រើអតិថិជន AIA Client Care

AIA Cambodia
TELEGRAM CHANNEL

**086 999 242 / 023 999 242,**
**kh.care@aia.com**
**aia.com.kh**
AIA Cambodia Telegram Channel

# ករណីមិនធានា

ផលិតផលធានារ៉ាប់រងបន្ថែមនេះ មិនធានាលើ៖

1. ជំងឺ ឬការវះកាត់ណាមួយ ដែលមិនមែនជាជំងឺធ្ងន់ធ្ងរដូចបានកំណត់ក្នុងតារាងជំងឺធ្ងន់ធ្ងរខាងលើ ឬ
2. រោគសញ្ញា ឬអាការៈរោគនៃអាការៈជំងឺធ្ងន់ធ្ងរ ដែលបានកើតឡើងក្នុងកំឡុងពេល 90 (កៅសិប) ថ្ងៃនៃថ្ងៃប្រតិទិន គិតចាប់ពីកាលបរិច្ឆេទនៃសុពលភាពបណ្ណសន្យារ៉ាប់រង ឬកាលបរិច្ឆេទដែលចូលជាធរមាននៃផលិតផលធានារ៉ាប់រងបន្ថែមនេះដោយយកកាលបរិច្ឆេទណាមួយចុងក្រោយគេ ឬ
3. អាការៈជំងឺធ្ងន់ធ្ងរកើតឡើងដោយផ្ទាល់ ឬដោយប្រយោលពីស្ថានភាពមុនពេលធានារ៉ាប់រងដូចបានកំណត់ ដែលកើតមាន មុនកាលបរិច្ឆេទនៃសុពលភាពបណ្ណសន្យារ៉ាប់រង ឬកាលបរិច្ឆេទដែលចូលជាធរមាននៃផលិតផលធានារ៉ាប់រងបន្ថែមនេះដោយយកកាលបរិច្ឆេទចុងក្រោយគេ ឬ
4. អាការៈជំងឺធ្ងន់ធ្ងរ ដែលតាមគំនិតរបស់ក្រុមហ៊ុន កើតមានដោយផ្ទាល់ ឬដោយប្រយោលពីវត្តមាននៃមេរោគអេដស៍ (AIDS ឬ HIV) និងលក្ខខណ្ឌផ្សេងៗដែលពាក់ព័ន្ធ។ ក្រុមហ៊ុនសូមរក្សាសិទ្ធិក្នុងការតម្រូវឱ្យអ្នកត្រូវបានធានារ៉ាប់រងទៅពិនិត្យឈាមរកវីរុសហ៊ីវ ដែលជាលក្ខខណ្ឌដំបូងបង្អស់ក្នុងការទទួលយកការទាមទារសំណងណាមួយ។ សម្រាប់គោលបំណងនៃផលិតផលធានារ៉ាប់រងបន្ថែមនេះ៖
   - (i) និយមន័យនៃ ជំងឺអេដស៍ (AIDS) ត្រូវតែជានិយមន័យដែលត្រូវបានប្រើ ដោយអង្គការសុខភាពពិភពលោកក្នុងឆ្នាំ 1987 ឬការកែប្រែណាមួយក្រោយមកទៀត ទៅលើនិយមន័យនោះដោយអង្គការសុខភាពពិភពលោក។
   - (ii) ការឆ្លងមេរោគនេះ ត្រូវចាត់ទុកថាបានកើតឡើងនៅពេលដែលការពិនិត្យឈាម ឬការពិនិត្យផ្សេងៗ ដែលពាក់ព័ន្ធ ហើយដែលតាមយោបល់របស់ក្រុមហ៊ុន បង្ហាញថាមានផ្ទុកវីរុសហ៊ីវ ឬអង់ទីករប្រឆាំងមេរោគនេះ។
5. រាល់ការធ្វើរោគវិនិច្ឆ័យលើអាការៈជំងឺធ្ងន់ធ្ងរណាមួយ ទោះដោយផ្ទាល់ ឬដោយប្រយោល ដែលបណ្តាលមកពីជំងឺ ឬពិការភាពពីកំណើត ឬដោយមេរោគពីកំណើត ដែលត្រូវបានពិនិត្យ ឬធ្វើរោគវិនិច្ឆ័យឃើញ មុនពេលអ្នកត្រូវបានធានារ៉ាប់រងមានអាយុ 17 (ដប់ប្រាំពីរ) ឆ្នាំ លើកលែងតែអាការៈជំងឺដែលបានចែងក្នុងបណ្ណសន្យារ៉ាប់រងនេះ ឬ
6. អាការៈជំងឺធ្ងន់ធ្ងរណាមួយ ដែលកើតឡើងដោយផ្ទាល់ពីការពិសាគ្រឿងស្រវឹង ឬប្រើប្រាស់ថ្នាំញៀនហួសកម្រិត ឬ
7. ព្រឹត្តិការណ៍ណាមួយដែលបង្កឲ្យមានការទាមទារសំណង ទៅលើអ្នកត្រូវបានធានារ៉ាប់រង ដែលបង្កឡើងដោយផ្ទាល់ ឬដោយប្រយោលដោយចេតនារបស់ម្ចាស់បណ្ណសន្យារ៉ាប់រង ឬបុគ្គលណាម្នាក់ដែលនឹងមានសិទ្ធិទទួលបានអត្ថប្រយោជន៍ដែលត្រូវបង់ជូន ឬ
8. ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រង មិនបានរស់រានមានជីវិតយ៉ាងហោចណាស់ 30 (សាមសិប) ថ្ងៃនៃថ្ងៃប្រតិទិន បន្ទាប់ពីការធ្វើរោគវិនិច្ឆ័យឃើញថាមានជំងឺធ្ងន់ធ្ងរ។

**ការិយាល័យកណ្ដាល**

អគារ ជីអាយអេ ថៅអឺរ ជាន់ទី31 ផ្លូវសុភមង្គល ភូមិ14 សង្កាត់ទន្លេបាសាក់
ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

**សាខាសៀមរាប**

អគារលេខ 29 និង 30
ផ្លូវហ្សាលដឺហ្គោល សាលាកន្សែង សង្កាត់ស្វាយដង្គំ ទីរួមខេត្តសៀមរាប

**សាខាបាត់ដំបង**

ផ្ទះលេខ 2-6ផ្លូវលេខ 3 ភូមិកម្មករ សង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង ខេត្តបាត់ដំបង

**សាខាកំពង់ចាម**

ភូមិ 15 សង្កាត់កំពង់ចាម ខណ្ឌកំពង់ចាម ខេត្តកំពង់ចាម

**សាខាកំពត**

ផ្លូវលេខ 700 ភូមិ 1ឧសភា សង្កាត់កំពង់កណ្ដាល ក្រុងកំពត ខេត្តកំពត

086 999 242 | AIA.COM.KH | AIA CAMBODIA